គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

CFC-CBC 11102012 K

# ស្ថានភាពយុទ្ធសាស្ត្រ នៃកោះត្រល់ និងខ្សែបន្ទាត់"ប្រេវិយេ"

*ដោយ* **ឌី ការ៉េត**

នាកណ្ដាលសតវត្សទី១៩ កម្ពុជាឋិតក្នុងស្ថានភាពទន់ខ្សោយជាខ្លាំង ថ្វីត្បិតតែបានរំដោះខ្លួន ចេញពីនឹមអាណានិគមយួនក្ដី ។ តាំងពីដើមសតវត្សហ្នឹងមក ពួកស្ដេចរាជាធិរាជយួន តែងចាត់ទុកកោះខ្មែរ "ត្រល់" (យួនហៅថា "ភូកុក") ថាជាទឹកដីនៃចក្រ-ភពអាណ្ណាម (យៀកណាម សព្វថ្ងៃ) ប៉ុន្តែខ្មែរក៏តែងតែជំទាស់ជាដាច់ខាត ជានិច្ចកាលដែរ ។ លុះបារាំងអាណានិគម ចូលមកត្រួត-ត្រាឥណ្ឌូចិន ពីកណ្ដាលសតវត្សទី១៩មក បារាំងមិនហ៊ានដោះស្រាយ អំពីបញ្ហាកម្មសិទ្ធិនៃកោះនេះទេ ។ ទាល់តែជិត១០០ឆ្នាំបន្ទាប់មក ទើបលោក ហ៊្សុល ប្រេវិយេ (Jules Brévié) ជាអគ្គទេសាភិបាលនៃឥណ្ឌូចិន បានសំរេចចិត្តម្នាក់ឯង នាថ្ងៃទី៣១ មករា ១៩៣៩ ដាក់កោះត្រល់ នៅក្រោមរដ្ឋបាលនៃដែនកូសាំងស៊ីន ដែលជាអាណានិគមរបស់បារាំង ដោយលោកបញ្ជាក់ដែរ ថាជាការសំរេចចិត្ត លើផ្នែករដ្ឋបាលប៉ុណ្ណោះទេ មិនមែនទៅលើបញ្ហាអធិបតេយភាព នៃកោះត្រល់ទេ ។

## កោះត្រល់ នាសតវត្សទី១៩

ឈ្មោះ" កោះត្រល់ " គឺជាឈ្មោះដែលខ្មែរបានស្គាល់ ជាយូរយាមកហើយ ។ គេបានឃើញពាក្យ"កោះ" សរសេរលើផ្ទាំងថ្មតាំងពីសម័យអង្គរ ។ នៅសតវត្សទី១៩ ពួកសៀមក៏ស្គាល់តែឈ្មោះ"កោះត្រល់" ដែលជាកោះរបស់ខ្មែរដែរ ។ ពាក្យយួន"ភូកុក" ប្រហែលជាកើតមាន កាលពេលស្ដេចយួនឈ្មោះ"ង្វៀង ភុក អាន់" ឬ"ង្វៀង អាន់"(អនាគតរាជាធិរាជ យ៉ា ឡុង) ដែលបានមកជ្រកនៅលើកោះត្រល់ហ្នឹង ពីឆ្នាំ១៧៨២ ទៅ១៧៨៦ ដោយពួកតៃសឺង វាយកំចាត់ពីអាណ្ណាម ហើយភៀសខ្លួនទៅស្រុកសៀមមុននិងមកសុំជ្រកកោន នៅស្រុកខ្មែរ ។ ស្ដេចយួន ង្វៀង ភុក អាន់ នេះ បានទាំងសុំជំនួយកងទ័ពធំខ្មែរមួយ ពីស្ដេចខ្មែរ ព្រះអង្គអេង ដើម្បីវិលទៅច្បាំងដណ្ដើមរាជ្យ ពីពួកតៃសឺងវិញផង[1] ។ ប៉ុន្តែ ទម្លាប់របស់ពួកយួន គឺគេផ្លាស់ឈ្មោះដើម នៃស្រុកទេសរបស់អ្នកជិតខាងទាំងអស់ ឱ្យមានជាឈ្មោះយួនវិញ ទោះជាគេបានទៅនៅទីនោះ ជាជនមកជ្រកកោនក្ដី និង មួយរយៈកាលក្ដី ។

នាខែមិថុនា ១៨៥៦ អ្នកការទូតបារាំង ឈ្មោះ សាល ដឺ ម៉ុងទីញី (Charles de Montigny) បានមកដល់ស្រុកសៀម ហើយបានចុះសន្ធិសញ្ញាមួយ នាខែសីហា ជាមួយសៀម ស្ដីពីពាណិជកម្មផង ពីសេរីភាពផ្សព្វផ្សាយសាសនា(កាតូលិក)ផង ពីការបើកផ្លូវឱ្យកុប៉ាល់ចំបាំងបារាំង ចូលទៅដល់ក្រុងបឹងកក់ផង ។ ខាងសៀម ក៏គេត្រូវការវត្តមានបារាំង មកនៅជិតខាងគេដែរ ដើម្បីជាការទប់ទល់និងពួកអង់គ្លេស ដែលកំពុងរាតទីអានុភាព យ៉ាងខ្លាំងក្លាណាស់ មកលើដែនសៀម ។ ជាបន្ទាប់មក រដ្ឋមន្ត្រីសៀមក្រសួងទ័ពជើងទឹក និងក្រសួងការបរទេស បានយកផែនទីនៃឆ្នេរសមុទ្រសៀម និងស្រុកខ្មែរ និងដែនកូសាំងស៊ីន ទៅពីគ្រោះជាមួយម៉ុងទីញី ឱ្យម៉ុងទីញីយល់អំពីប្រយោជន៍សេដ្ឋកិច្ច នៃ"កូ ត្រូល"(កោះត្រល់) ហើយឱ្យយកកោះនេះ ជាកម្មសិទ្ធិរបស់បារាំងទៅ ។ លុះម៉ុងទីញី មកដល់ខែត្រកំពត គាត់បានឃើញថាកោះត្រល់ "អាចរៀបចំ ជាផែសមុទ្រមួយយ៉ាងប្រសើ និងជាទីតាំង ពាណិជ្ជ-កម្មមួយយ៉ាងធំ នៅកណ្ដាលដែនឥណ្ឌូចិនផង" ។ ប៉ុន្តែ ម៉ុងទីញី មិនចង់ធ្វើដំណើរ (ដោយលេសថាផ្លូវពិបាក) ទៅជួបព្រះបាទអង្គឌួង ឯក្រុងឧត្តុងទេ ហើយគាត់ចាត់ឱ្យលោកសង្ឃកាតូលិក ឈ្មោះ អារសែន អេសត្រេស (Arsène Hestrest) នាំយកទៅថ្វាយព្រះអង្គឌួង នូវសំបុត្រមួយ ដែលគាត់ស្នើឱ្យកម្ពុជា ប្រគល់កោះត្រល់ឱ្យបារាំង ជាថ្នូរនិងគំរូសន្ធិសញ្ញា ដែលបារាំងបានធ្វើជាមួយ

[1] Lettre du Roi ANG DUONG à l'Empereur NAPOLEON III du 25 novembre 1856.

សៀម ពីខែសីហាមុននោះ ។ ព្រះបាទអង្គឌួង មិនព្រមទទួលសេចក្តីស្នើនេះទេ ដោយលោកយល់ថា សន្ធិសញ្ញាបែបហ្នឹង មិនបានធានាច្បាស់លាស់ ចំពោះ“សន្តិសុខ” (ការរស់រានជានិច្ច) នៃកម្ពុជាទេ...។ ដោយឡែក នាសម័យនោះដែរ ពួកអង់គ្លេសក៏បានមកពិនិត្យមើលកោះត្រល់ដែរ (គេហៅថា“កោះឌូត” - Koh Doot) ហើយនិយាយថាជា “កោះមួយមានសារៈសំខាន់ណាស់សំរាប់ការប្រើប្រាស់ នៃកងនាវាសមុទ្រ” នៅតាមផ្លូវដំណើរទៅក្រុងសឹងកាពួរ (Singapour)[2]។ ការពិត កោះត្រល់នេះ ជាកោះធំជាងគេបំផុត មានទំហំប្រមាណ៥៨០គ.ម.ក្រឡា នៅក្នុងឈូងសមុទ្រសៀម និងនៅមាត់ផ្លូវចូល នៃឈូងសមុទ្រហ្នឹងផង ។

## ការដណ្តើមគ្នា គ្រប់គ្រងកោះត្រល់

នៅខាងខ្មែរវិញ កោះត្រល់ស្ថិតក្រោមការគ្រប់គ្រងរបស់កម្ពុជា ដូចការបញ្ជាក់ ពីទេសាភិបាលបារាំង នៃដែនកូសាំងស៊ីន ដែលសរសេរទៅរដ្ឋមន្ត្រីរបស់គាត់ នាឆ្នាំ១៨៦៧ ថាអភិបាលយួននៃខែត្រហាទៀង “មិនដែលបានចុះទៅមើលការងារអ្វី នៅកោះត្រល់ទេ”[3]។ នាថ្ងៃទី៣ មករា ១៩១៣ គឺ៣៦ឆ្នាំបន្ទាប់មក អភិបាលយបារាំងនៃខែត្រហាទៀង ឈ្មោះ ហ្វូរនីយេ (Fournier) បានធ្វើរបាយការណ៍ ទៅទេសាភិបាលបារាំង នៃកូសាំងស៊ីន ថា“បន្ទាប់ពីការស្រាវជ្រាវយ៉ាងល្អិតល្អន់មក ខ្ញុំមិនបានរកឃើញទេ នៅក្នុងកំណប់ឯកសារ នៃអធិការដ្ឋានយើង នូវឯកសារជាផ្លូវការណាមួយ ទោះមានទ្រង់ទ្រាយយ៉ាងណាក្តី ដែលបង្ហាញថាតើកោះណាខ្លះ ជាចំណុះនៃខែត្រហាទៀង គឺថា តើកោះណាខ្លះ ជារបស់កូសាំងស៊ីន ហើយកោះណាខ្លះទៀត ជារបស់កម្ពុជា”[4]។ ចាប់ពីឆ្នាំ១៩១៣នោះដែរ គេបានផ្អើលម្តងទៀត អំពីប្រយោជន៍សេដ្ឋកិច្ច នៃកោះនៅតាមឆ្នេរសមុទ្រខ្មែរ មានកោះត្រល់ជាអាទិ ។ លោកទេសាភិបាលនៃកូសាំងស៊ីន បានសរសេរសំបុត្រមួយ ចុះថ្ងៃទី២ មករា ១៩១៤ ប្រាប់មកអ្នកតំណាងជាន់ខ្ពស់បារាំង នៅកម្ពុជា (le Résident supérieur du Cambodge) ថាលោកបានទទួលពាក្យស្នើជាច្រើន សុំសម្បទានដីធ្លី ដើម្បីការរុករករ៉ែ (នៅលើកោះទាំងនោះ) ជាមួយនិងការរកឃើញទៀតថា “ទឹកដែលនៅជុំវិញកោះទាំងនោះ មានត្រីរស់នៅសន្ធឹកសន្ធាប់ណាស់...(តែ) គ្មាននរណាទាញយកផល អំពីធនធានទាំងនេះ ដែលជាមូលធនមួយសំខាន់ណាស់ និងជាប្រយោជន៍ពិតប្រាកដ សំរាប់អាណានិគម (បារាំង)”។ រីឯអ្នកតំណាងបារាំង នៅខែត្រកំពត ក៏បានទទួលពាក្យស្នើជាច្រើន សុំសម្បទានដីធ្លី ដើម្បីការរុករករ៉ែ នៅលើកោះដែលនៅក្រោមការគ្រប់គ្រង របស់គាត់ដែរ ។ ហេតុនេះ នាឆ្នាំ១៩១៣ និង១៩១៤នោះ អ្នកទទួលការខុសត្រូវបារាំង នៅកូសាំង-ស៊ីន និងនៅកម្ពុជា បានប្តូរសំបុត្រទៅវិញទៅមក ទាមទារកម្មសិទ្ធិនៃកោះផ្សេងៗនោះ តែលោកអគ្គទេសាភិបាលនៃឥណ្ឌូចិន ជាបន្តបន្ទាប់ ដែលជា“ចៅហ្វាយធំបំផុត” មិនបានសំរេចអ្វីឡើយ ដោយពិតជាខ្លាចទាស់ និងសន្ធិសញ្ញានានា រវាងបារាំងនិងកម្ពុជា ។ ទាល់តែ២៥ឆ្នាំបន្ទាប់មកទៀត ទើបលោក ហ្ស៊ុល ប្រេវិយេ (ដែលមកកាន់ការឥណ្ឌូចិន តាំងពីខែកញ្ញា១៩៣៦) សំរេចចិត្ត អំពីបញ្ហាហ្នឹង ដោយចេញសារាចរ ធ្វើខ្សែបន្ទាត់មួយ ចែក“កិច្ចរដ្ឋបាល”នៃកោះនានា ចុះថ្ងៃទី៣១ មករា ១៩៣៩ ប្រាប់ទៅលោកទេសាភិបាល នៃកូសាំងស៊ីន ។

ការសំរេច របស់ប្រេវិយេ អំពីបញ្ហានេះ នៅឆ្នាំ១៩៣៩ ពិតជាទាក់ទិននិងស្ថានភាព នៃប្រទេសបារាំង នាសម័យនោះដែរ ។ ចាប់ពីឆ្នាំ១៩៣០មក ប្រទេសបារាំងបានរងគ្រោះធ្ងន់ធ្ងរ និងវិបត្តិសេដ្ឋកិច្ចនៃបស្ចិមប្រទេស ដែលជំរុញឱ្យមានការបះបោរ ជាបន្ត-បន្ទាប់ក្នុងសង្គម នាឆ្នាំ១៩៣៤ និងបណ្តាលឱ្យកើតវិបត្តិនយោបាយ ដែលធ្វើឱ្យប្រទេសទាំងមូល ចុះទន់ខ្សោយ ហើយរលំទាំង-ស្រុង យ៉ាងរហ័ស នៅមុខការវាយរាតត្បាត នៃទ័ពអាល្លឺម៉ាញ របស់ហ៊ីត្លែរ នាខែឧសភា ១៩៤០ ។ ក្នុងរយៈកាលនោះ នៅឯឥណ្ឌូចិន ក៏ដូចនៅប្រទេសបារាំងដែរ ពួកបារាំងគ្រាន់តែខំទប់ខ្លួន ឱ្យបាននៅឈរជើង ដោយគ្មានគម្រោងការអ្វីធំដុំទេ ក្នុងការរង់ចាំមើល ការវិវត្តន៍នៃព្រឹត្តការណ៍ នៅទ្វីបអឺរ៉ុប និងនៅក្នុងពិភពលោក ។ ព្រឹត្តការណ៍ធំមួយ គឺនាថ្ងៃទី៧ កក្កដា ១៩៣៧ កងទ័ពជប៉ុន ចូលវាយលុកប្រទេសចិន ផ្នែកខាងកើត ហើយកាន់កាប់ទីក្រុងស៊ាំងហៃ នាខែវិច្ឆិកា រួចវាយយកបានរដ្ឋធានីណាន់-គីងទៀត ។ នៅក្នុងឯកសារបារាំងមួយ នៃនាយកដ្ឋានកិច្ចការនយោបាយ ចុះលេខ៣៦៧-អាប៉េអ៊ី ស្តីពីកោះនានា នៅក្នុងឈូងសមុទ្រ

---

[2] in Charles MEYNIARD, *Le Second Empire en Indochine (Siam-Cambodge-Annam)*, Société d'Editions Scientifiques, Paris 1891.

[3] SARIN CHHAK, *Les Frontières du Cambodge*, Tome I, Paris, Dalloz, 1966, p. 153

[4] SARIN CHHAK, *Les Frontières du Cambodge*, Tome I, Paris, Dalloz, 1966, p. 153

សៀម គេបានសរសេរថា “សារាចររបស់លោកអគ្គទេសាភិបាល ប្រេវិយេ ចុះថ្ងៃទី៣១ មករា ១៩៣៩ បានធ្វើឡើងស្របតាមការចាំបាច់ នៃកិច្ចការពារឥណ្ឌូចិនដែរ ដោយហេតុថានាពេលនោះ ជប៉ុនបានកាន់កាប់ប្រទេសចិន ផ្នែកខាងកើតហើយៗ ជាពេលដែលសង្គ្រាម នៅមហាសាគរប៉ាស៊ីហ្វិក បានចាប់ផ្ដើមហើយផង” ។ នាពេលនោះទៀត កងទាហ៊ានជើងទឹកបារាំង (នៅឥណ្ឌូចិន) ក៏បានទទួលបញ្ជាឱ្យ“ត្រួតពិនិត្យទូក-កុប៉ាល់ទាំងអស់ កុំឱ្យមានការដឹកជញ្ជូនគ្រឿងសព្វាវុធ ទៅឱ្យពួកបះបោរ ឬឱ្យពួកចូលដៃ និងកងកម្លាំងជប៉ុនឡើយ”[5] ។ ប៉ុន្តែ នៅក្នុង“សារាចរ”របស់គាត់ ប្រេវិយេ មិនបន្លឺអំពីបញ្ហានយោបាយ និងយោធាទាំងនេះ ជាការសំអាងអ្វីទេ ។

## ភាពច្របូកច្របល់ ក្នុងសារាចរ“ប្រេវិយេ”

យើងបានឃើញថា ដោយហេតុមានការទាមទារ ជាយូរមកហើយ ពីព្រះបាទអង្គឌួង ពួកបារាំងបានទុកកោះនានា នៃឆ្នេរសមុទ្រ គឺទាំងកោះត្រល់ រហូតដល់ប្រជុំកោះក្រចកសេះ (ពូឡូ ប៉ង់យ៉ង) ឱ្យនៅក្រោមអំណាចនៃកម្ពុជា ។ រីឯ“សារាចរ”របស់លោក ប្រេវិយេ គឺជាការសំរេចចិត្តម្នាក់ឯង -“ខ្ញុំសំរេចចិត្ត...”- នៃអគ្គទេសាភិបាលនៃឥណ្ឌូចិន ដោយគ្មានការយល់ព្រម ពីអាជ្ញាធរខ្មែរទេ ហើយនេះជាការបំពានយ៉ាងជាក់ស្ដែង លើសន្ធិសញ្ញានានា រវាងបារាំងនិងកម្ពុជា នាទសវត្ស១៨៧០ ។ ហេតុនេះ ដើម្បីលុបលាងការរំលោភអំណាចរបស់គាត់ និងដើម្បីដាក់កំរឹតដល់ការអនុវត្តន៍ នៃសេចក្ដីសំរេចចិត្តនោះផង ប្រេវិយេបានទទួលស្គាល់ ជាបឋមបំផុតថា កោះទាំងនោះ“ឋិតនៅតាមបណ្ដោយឆ្នេរសមុទ្រកម្ពុជា” និងថា“តាមការសមហេតុផល និងតាមស្ថានភាពភូមិសាស្ត្រ” កោះទាំងនោះ ត្រូវនៅក្រោមការគ្រប់គ្រងនៃប្រទេសកម្ពុជា ។ បន្ទាប់មក គាត់បញ្ជាក់ថា សេចក្ដីសំរេចចិត្តហ្នឹង គ្រាន់តែបែងចែក“អំណាចរដ្ឋបាលកិច្ចនិងអំណាចប៉ូលីស នៅលើកោះ រវាងកូសាំងស៊ីននិងកម្ពុជាប៉ុណ្ណោះ” តែគាត់មិនអារកាត់ លើបញ្ហាកម្មសិទ្ធិនៃកោះទេ ដោយថា“ត្រូវបំរុងទុកទាំងស្រុងដដែល” (“*la dépendance territoriale de ces îles reste entièrement réservée*”) - ប្រហែលដើម្បីសំរន់ចិត្ត របស់ពួកកូសាំងស៊ីន ជាគ្នីគ្នារបស់គាត់ ។ យើងឃើញថា សេចក្ដីសំរេចចិត្តហ្នឹង វាប្លែកខុសពីសេចក្ដីសំរេចចិត្តនានា នៃអគ្គទេសាភិបាលដ្ឋាននៃឥណ្ឌូចិន ដោយមានភាពច្របូកច្របល់គ្នា នូវជំនឿច្បាស់លាស់ផង នូវការសំអាងកំប៉ិចកំប៉ុកផង (ការសំរួលដំណើរ នៃអ្នកចង់ទាក់ទងនិងរដ្ឋការកូសាំងស៊ីន) ជាមួយនិងការទុកប្រចាំ នៃម្ចាស់សេចក្ដីផង ដែលជាលក្ខណៈ នៃការសំរេចចិត្តមួយ ជាបណ្ដោះអាសន្នប៉ុណ្ណោះ ឱ្យស្របតាមទេសៈកាលៈអសន្តិសុខ នៅក្នុងតំបន់។ ម្យ៉ាងទៀត ខ្សែបន្ទាត់នៃការបែងចែកសោត ក៏ជាការបង្កើតថ្មីមួយ ក្នុងរឿងដែនសមុទ្រ ÷ គឺមិនមែនជាខ្សែបន្ទាត់ត្រង់រហូតទេ តែជាខ្សែដែលចេញពីដែនដី យ៉ាងត្រង់មក រួចបត់ដូចជាផ្លែកណ្ដៀវ ទៅព័ទ្ធចាប់យកកោះត្រល់ ឱ្យទៅកូសាំងស៊ីន ហើយឈប់ត្រឹមហ្នឹង ។ តាមធម្មតា គឺគ្មានអ្នកនិតិសាស្ត្រម៉ត់ចត់ណាម្នាក់ យល់ថាការសំរេចចិត្តបែបនេះ មានតំម្លៃអ្វីទេ ។ ហេតុនេះ សារាចរ“ប្រេវិយេ” ត្រូវបានកម្ពុជាច្រានចោលជានិច្ច បន្ទាប់ពីកម្ពុជាបានឯករាជ្យ នាឆ្នាំ១៩៥៣ ។ រហូតមកដល់ឆ្នាំ១៩៧៩ (ដែលយួនចូលកាន់កាប់កម្ពុជា) រដ្ឋាភិបាលខ្មែរជាបន្តបន្ទាប់ទាំងអស់ តែងតែចាត់ទុកកោះត្រល់ ប្រជុំកោះក្រចកសេះ (ពូឡូ ប៉ង់យ៉ង) និងកោះវៃ (ពូឡូ វៃ) នៅក្នុងដែនសមុទ្រកម្ពុជា ជានិច្ច ។

បន្ទាប់ពីបារាំងរំលាយអាណានិគម នាឆ្នាំ១៩៤៩ និងបន្ទាប់ពីបានឯករាជ្យ មកដល់ឆ្នាំ១៩៧៥ ទោះបីគេបានធ្វើការបំរុងទុក (des réserves) និងការទាមទារតាមផ្លូវទូត ជាច្រើនសន្ទឹកក្ដី ក៏កម្ពុជាមិនដែលប្រើកម្លាំងទ័ព ដើម្បីទៅដណ្ដើមយកកោះត្រល់មកកាន់កាប់ផ្ទាល់ដៃវិញទេ ។ ការទាមទារតាមផ្លូវតុលាការអន្តរជាតិ ដូចក្នុងរឿងប្រាសាទព្រះវិហារ ក៏គ្មានដែរ ។ ប៉ុន្តែ ប៉ុល ពត ដែលយល់អំពីសារៈសំខាន់ នៃស្ថានភាពយុទ្ធសាស្ត្រ នៃកោះត្រល់និងកោះជិតខាងឯទៀតនោះ បានឱ្យកងទ័ពចូលទៅប្រយុទ្ធ និងកងទ័ពយួន នាដើមខែឧសភា ១៩៧៥ ដោយបានកាន់កាប់កោះត្រល់មួយភាគធំ និងកោះក្រចកសេះ ។ ការចរចាគ្នា រវាងប៉ុល ពត និងយួន នៅក្រុងហាណូយ នាខែមិថុនា ១៩៧៥ បានបន្ធូរបរិយាកាសខ្លះដែរ តែដល់ថ្ងៃទី៤ មករា ១៩៧៦ ការប្រយុទ្ធគ្នា

[5] *Le Relèvement – 1944-1949*, par Pierre GERBET, Professeur émérite des Universités, Imprimerie Nationale, Paris. 1991.

យ៉ាងខ្លាំងមួយទៀត បានផ្ទុះឡើង រវាងកងទ័ពខ្មែរក្រហមនៅកោះត្រល់ និងកងទ័ពជើងទឹក និងជើងអាកាសយួន[6] ។ ពួកខ្មែរ-ក្រហមត្រូវដកខ្លួនទាំងអស់ ចេញពីកោះត្រល់ ប៉ុន្តែបរាជ័យនេះ មិនមានន័យថា កម្ពុជាត្រូវបាត់បង់សិទ្ធិដ៏ត្រឹមត្រូវរបស់ខ្លួន ទៅលើកោះត្រល់ និងកោះក្រចកសេះ ទាំងនោះដែរទេ ។ យៀកណាមបានកាន់កាប់កោះទាំងនោះ ដោយកម្លាំង រហូតដល់ខែធ្នូ ១៩៧៨ ដែលគេបានសំរេច ចូលវាយប្រហារកម្ពុជាទាំងមូល ។ ក្នុងពេលគេកាន់កាប់កម្ពុជា យួនបានសំរេចកាត់យកកោះត្រល់ និងក្រុមកោះក្រចកសេះ បញ្ចូលទៅក្នុងយៀកណាម ដោយគ្មានសំអាងលើកត្តាអ្វីទេ ក្រៅពីយោងតាម"សភាពការណ៍ជាក់ស្តែង" (គឺការកាន់កាប់របស់គេ ជាស្រេចហើយ) តាមរយៈកិច្ចព្រមព្រៀងមួយ ចុះថ្ងៃទី៧ កក្កដា ១៩៨២ ជាមួយបុគ្គលម្នាក់ឈ្មោះ ហ៊ុន សេន ។ ក្នុងកិច្ចព្រមព្រៀងនោះ គេបានបង្កើតនៅមុខកោះត្រល់ នូវ"សមុទ្រផ្ទៃក្នុងរួមគ្នា"យៀកណាម-កម្ពុជា មានទំហំប្រមាណ១០ ០០០ គ.ម.ក្រឡា ដែលគេហៅថា"តំបន់ទឹកប្រវត្តិសាស្ត្រ" ដែលមានលទ្ធផល ជាការពង្រីកអធិបតេយ្យយួន ចូលមកជ្រៅទៀត ក្នុងដែនសមុទ្រខ្មែរ ក្នុងនាមនៃការចាំបាច់ នៃ"កិច្ចការពារជាតិ នៃប្រទេសទាំងពីរ" ។ នេះគឺជាការណ៍ជាក់ស្តែងដែរ នៃកិច្ចព្រមព្រៀងមួយ មិនស្មើរភាពគ្នា និងខុសច្បាប់អន្តរជាតិទាំងស្រុង ដែលត្រូវបានអង្គការសហប្រជាជាតិបរិហា នាឆ្នាំ១៩៨៦ ហើយត្រូវកិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងប៉ារីស ស្តីពីកម្ពុជា នាឆ្នាំ១៩៩១ បញ្ជាឱ្យលុបចោល ។

## ខ្មែរត្រូវយកកោះត្រល់ មកវិញ

យើងបានឃើញថា យៀកណាមកុម្មុយនីស្ត៍ ដែលបានក្លាយជាមហាអំណាចយោធា មិនទទួលស្គាល់សារៈសំខាន់ នៃខ្សែបន្ទាត់ "ប្រេវិយេ"ទេ ។ ប៉ុន្តែ ការមិនទទួលស្គាល់ខ្សែបន្ទាត់នេះ នៃកម្ពុជាវិញ ក៏ជាការសមស្រប និងគោលការណ៍ច្បាប់ ដែលកើតពីការសំរេចរបស់បារាំង រំលាយអាណានិគមកូសាំងស៊ីន របស់គេ នាឆ្នាំ១៩៤៩ដែរ ។ យើងបានឃើញខាងលើនេះ ថាពួកអាណានិគម-និយមបារាំង រួមទាំងប្រេវិយេនោះផង បានដឹងច្បាស់ថា កោះត្រល់ជាពិសេស មិនមែនជាកោះធម្មតាទេ តែវាមានលក្ខណៈ តាមភូគព្ភសាស្ត្រ ដូចជាទៀបកោះដែលមានមួយភាគលិចទឹក ព្រោះវាជាដីបន្តចុះមក ពីជួរភ្នំក្រវាញ នៃកម្ពុជា ។ អាស្រ័យហេតុនេះហើយ ទើបបារាំងទាំងនោះ មិនហ៊ានសំរេចយកកោះត្រល់ ទៅបញ្ចូលក្នុងដែនកូសាំស៊ីន ទោះបីគេមានអំណាចធំធេង លើកម្ពុជា តាំងពីឆ្នាំ១៨៦៣មកក្តី ។ ម្យ៉ាងទៀត សារាចរ"ប្រេវិយេ" ដែលគ្រាន់តែជាការសំរេចចិត្ត នៃកិច្ចការរដ្ឋបាលផ្ទៃក្នុង មិនមានកម្លាំងដូចសន្ធិសញ្ញាអន្តរជាតិ ឬ ដូចជាច្បាប់ផ្ទៃក្នុងរបស់កម្ពុជាទេ ពីព្រោះកម្ពុជា មិនមែនជាអាណានិគម របស់បារាំងទេ តែជារដ្ឋមួយ ដែលបារាំងធ្វើជាអ្នកអាណាព្យាបាល (អ្នកការពារ ក្នុងកិច្ចការក្រៅប្រទេស) ។ ជាពិសេស ខ្សែបន្ទាត់"ប្រេវិយេ" មានលក្ខណៈច្បាស់ ថាជាខ្សែបន្ទាត់ នៃការរំលោភអំណាច និងជាការកំណត់បណ្តោះអាសន្ន ដែលត្រូវរលាយបាត់ ជាស្វ័យប្រវត្ត នាពេលដែលបារាំងរំលាយអាណានិគមកូសាំងស៊ីន របស់ខ្លួនដែរ ។ ហេតុនេះ ខ្សែបន្ទាត់"ប្រេវិយេ" មិនអាចចាត់ទុកថាជាខ្សែបន្ទាត់ព្រំដែនសមុទ្រ រវាងកម្ពុជានិងយៀកណាមទេ ហើយគេមិនត្រូវចាត់ទុកវា យ៉ាងហ្នឹងឡើយ ។ ការពិត កោះត្រល់និងកោះឯទៀត នៅជិតឆ្នេរសមុទ្រខ្មែរ សុទ្ធជាដីដែលដុះបន្តតាមធម្មជាតិ របស់កម្ពុជា គឺថាជារបស់ប្រជាជាតិ ដែលនៅជិតកោះទាំងនេះ ហើយវាកំណត់ដែនទឹកសមុទ្រ និងព្រំដែនអធិបតេយ្យ នៃប្រជាជាតិហ្នឹង ។ សារៈសំខាន់បំផុតនៃកោះទាំងនោះ មិននៅក្នុងរឿងប្រយោជន៍សេដ្ឋកិច្ចទេ (ដូចជាធនធានជលផល និងធនធានរ៉ែ ឬ ប្រេងកាត ជាយថាហេតុ) តែនៅក្នុងរឿងយុទ្ធសាស្ត្រយោធា ត្បិតកោះទាំងនោះ សុទ្ធសឹងជាប៉ុស្តិ៍ខាងមុខ នៃកិច្ចការពារជាតិ របស់កម្ពុជា ។ ខ្មែរត្រូវតែខំប្រឹងប្រែង រកគ្រប់មធ្យោបាយ យកកោះត្រល់ និងកោះឯទៀតនោះ មកគ្រប់គ្រងវិញ ។ ការបោះបង់ទឹកដីជាតិបែបនេះ ឱ្យទៅអំណាចបរទេស គឺជាអំពើក្បត់មួយយ៉ាងធំបំផុត ចំពោះប្រជាជាតិ របស់ខ្លួន ។

*ទីក្រុងប៉ារីស ថ្ងៃទី១១ តុលា ២០១២*

ជ.គណកម្មាធិការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង និងក្នុពិភពលោក

**ឌី ការ៉េត**

[6] The Son Sen Files, 1976-1977, NR34 Report to Brother 89 http://www.yale.edu/cgp/sonsenfiles.html